- នាយកដ្ឋានសិក្សាអន្តរជាតិ : មានមុខងារសម្របសម្រួលការសិក្សាស្រាវជ្រាវកិច្ចការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សំដៅបណ្តុះបណ្តាលជំនាញការសិក្សាអន្តរជាតិ។

## ជំពូកទី១២
## នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

**មាត្រា ៣៤.-**

នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានជាសេនាធិការឱ្យក្រសួងការបរទេសនិងសហប្រតិបត្តិការ

អន្តរជាតិ លើការងារគ្រប់គ្រង និងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ព្រមទាំងការគ្រប់គ្រង និងផ្សព្វផ្សាយព័ត៌មាន និងឯកសារ ។

## ជំពូកទី១៣
## នាយកដ្ឋានគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ

**មាត្រា ៣៥.-**

នាយកដ្ឋានគោលនយោបាយនិងផែនការយុទ្ធសាស្ត្រ ជាសេនាធិការឱ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លើការងារសម្របសម្រួលរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

## ជំពូកទី១៤
## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា៣៦.-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង បំពេញមុខងារជាសេនាធិការឱ្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ លើការងារពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ តាមស្មារតីខ្លឹមសារនៃអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាក្រសួងស្ថាប័ន និងសហគ្រាសសាធារណៈ។

## ជំពូកទី១៥
## ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស

**មាត្រា៣៧.-**

ស្ថានឯកអគ្គរាជទូត ស្ថានតំណាង ឬ ស្ថានបេសកកម្មអចិន្ត្រៃយ៍នានាប្រចាំអង្គការតំបន់ និងអង្គការអន្តរជាតិ ត្រូវដឹកនាំដោយឯកអគ្គរាជទូតជាប្រធានបេសកកម្ម។

ការតែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់បេសកកម្មឯកអគ្គរាជទូត ត្រូវស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីទូលថ្វាយព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា។

ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព គឺតំណាងឱ្យរាជរដ្ឋាភិបាលលើគ្រប់វិស័យ។

**មាត្រា៣៨.-**

ស្ថានអគ្គកុងស៊ុល ត្រូវដឹកនាំដោយអគ្គកុងស៊ុលជាប្រធានបេសកកម្ម។

ស្ថានកុងស៊ុល ត្រូវដឹកនាំដោយកុងស៊ុលជាប្រធានបេសកកម្ម។

អគ្គកុងស៊ុល ត្រូវជ្រើសរើសនិងស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជូនប្រមុខរាជរដ្ឋាភិបាល។

កុងស៊ុល និងកុងស៊ុលកិត្តិយស ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

## ជំពូកទី១៦
## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា៣៩.-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុបង្កើតឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមលក្ខខណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ៨១អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង។

## ជំពូកទី១៧
## អវសានប្បញ្ញត្តិ

**មាត្រា៤០.-**

អនុក្រឹត្យនេះ ត្រូវជំនួសអនុក្រឹត្យដូចខាងក្រោម៖

- អនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- អនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ស្តីពីការបង្កើតនាយកដ្ឋានសហប្រតិបត្តិការមេគង្គ
- អនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- អនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០១ ស្តីពីការបំបែកនាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក ជានាយកដ្ឋានអាស៊ីទី១ និងនាយកដ្ឋានអាស៊ីទី២។

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារៈកិច្ច រៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**

**ប្រាក់ សុខុន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ[illegible] អនក្រ.បក
ចុះថ្ងៃទី[illegible]ខែ ធ្នូ ឆ្នាំ២០១៦

# អង្គការលេខរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ




១៩

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១.៧៣៤...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា១**.-បំពាក់ **មេដាយសហមេត្រី ថ្នាក់ សេនា** ជូនវរសេនីយ៍ឯក DAO CONG VINH ទីប្រឹក្សាអមស្ថានទូតសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការរវាងនគរបាលនៃប្រទេសទាំងពីរ លើការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់កងកម្លាំងនគរបាលជាតិកម្ពុជា កន្លងមក ។

**មាត្រា២**.-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ៨ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៤៣៥ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូតជាន់ខ្ពស់**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សម្រេច**

**មាត្រា ១** : ត្រូវបានផ្លាស់លោកស្រី **ផែន សាវនី** ទីប្រឹក្សានៃស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ៨ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២៣៦ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា ១** : ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ០៣រូប របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិៈ

១. លោក **ផៃ គឹមឈន** បច្ចុប្បន្នអនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋានអាហ្វ្រិក មជ្ឈិមបូព៌ានៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជា **ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋឥណ្ឌា។

២. លោកស្រី **ឌី ឃឿន** បច្ចុប្បន្នអនុប្រធាននាយកដ្ឋាននៃនាយកដ្ឋានព័ត៌មាន និងឯកសារនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជា **ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសហភាពមីយ៉ាន់ម៉ា។

៣. លោក **អុច សុធី** បច្ចុប្បន្នមន្ត្រីថ្នាក់ប្រធានការិយាល័យនៃនាយកដ្ឋានរដ្ឋបាលនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជា **ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ១៤៩ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង
## ដើម្បីរៀបចំការសម្តែងសិល្បៈរួមអាស៊ាន-ចិន ឆ្នាំ២០១៦
(ASEAN-China Joint Cultural Performance 2016)
## ពីថ្ងៃទី២៦-២៧-២៨ ខែធ្នូ ឆ្នាំ២០១៦ នៅខេត្តសៀមរាប
## ក្រោមប្រធានបទៈ "ការតភ្ជាប់ក្នុងភាពចម្រុះគ្នា"

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៩៩៦/១៥ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ដែលបានប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងលិខិតលេខ ៩៧១៨ អស៊ី៦/កបទ.សអ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្តីពីសំណើសហការរៀបចំការសម្តែងសិល្បៈរួមអាស៊ាន-ចិន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

## សម្រេច

**ប្រការ១:_**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំការសម្តែងសិល្បៈរួមអាស៊ាន-ចិន ក្រោមប្រធានបទ "ការតភ្ជាប់ក្នុងភាពចម្រុះគ្នា" (ASEAN-China Joint Cultural Performance: Connectivity in Diversity) ពីថ្ងៃទី២៦-២៧-២៨ ខែធ្នូ ឆ្នាំ២០១៦ នៅខេត្តសៀមរាប ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១.ឯកឧត្តម **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២. លោកជំទាវ **ភឿង សកុណា** | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៣. លោកជំទាវ **សឿង រដ្ឋចាវី** | រដ្ឋលេខាធិការក្រសួងការបរទេសនិង | |
| | សហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៤. ឯកឧត្តមវេជ្ជ. **តែ គុយស៊ាង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៥. ឯកឧត្តម **ឃឹម ប៊ុនសុខ** | អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | អនុប្រធាន |
| ៦. ឯកឧត្តម **ទិត ចន្ថា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៧. ឯកឧត្តម **ជា ម៉ូរ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៨. ឯកឧត្តម **ប៉ាក់ សុខុម** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៩. លោកជំទាវ **ម៉ិញ្ញ កុសនី** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ១០. ឯកឧត្តម **លុយ ដាវីត** | រដ្ឋលេខាធិការក្រសួងការបរទេស និង | |
| | សហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ១១. ឯកឧត្តម **ជា ចាន់បរិបូរណ៍** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | អនុប្រធាន |
| ១២. ឯកឧត្តម **ហ៊ៅល ចំរើន** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៣. ឯកឧត្តម **ភាន់ ផារិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងការបរទេស និង | |
| | សហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៤. ឯកឧត្តម **គុណា ញឹម** | អគ្គនាយកគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ១៥. ឯកឧត្តម **ភីម គុណាវឌ្ឍន៍** | ប្រតិភូរាជរដ្ឋាភិបាល-អគ្គនាយកទូរទស្សន៍ជាតិកម្ពុជា | សមាជិក |
| ១៦. ឯកឧត្តម **អ៊ូក សោភ័ណ** | អគ្គនាយកនៃអគ្គនាយកដ្ឋានអាស៊ាននៃក្រសួង | |
| | ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៧. ឯកឧត្តម **ឈោប សាមុត** | អគ្គនាយកទេសចរណ៍នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៨. ឯកឧត្តម **គង់ សូលីដា** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួង | |
| | ទេសចរណ៍ | សមាជិក |
| ១៩. ឯកឧត្តម **ហាប់ ទូច** | អគ្គនាយកបច្ចេកទេសនៃក្រសួងវប្បធម៌ | |
| | និងវិចិត្រសិល្បៈ | សមាជិក |
| ២០. ឯកឧត្តមឧត្តមសនីយ៍ឯក **ទូច ណារុថ** អគ្គស្នងការរងនគរបាលជាតិ | | សមាជិក |
| ២១. ឯកឧត្តមឧត្តមសនីយ៍ឯក **ខង្វ ពិសេន** មេបញ្ជាការរង និងជានាយសេនាធិការ | | |
| | នៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ២២-ឯកឧត្តមឧត្តមសេនីយ៍ឯក **ឃុន សំបូរ** អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេស្តន៍ | | |
| | នៃក្រសួងមហាផ្ទៃ | សមាជិក |
| ២៣. ឯកឧត្តម **ហុក ប៉ែងសែ** | អគ្គនាយករងអាជ្ញាធរអប្សរា | សមាជិក |
| ២៤. លោក **យៀប សំណាង** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអាស៊ាន | |
| | ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២៥. លោកស្រី **ថោង សុគន្ធារី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអាស៊ាននៃ | |
| | ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

២៦. លោក **តិន ទិដ្ឋាវឌ្ឍនា** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងគណនេយ្យនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

២៧. លោក **ខៀវ រិទ្ធីយ៉ា** ប្រធាននាយកដ្ឋានពិធីការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

២៨. លោក **ជូ សំណាង** ប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុល នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

២៩. លោក **ហុក សុតា** ប្រធាននាយកដ្ឋានសារព័ត៌មាននៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

គណៈកម្មការនេះ មានតួនាទី និងភារកិច្ចដឹកនាំ និងសម្របសម្រួលការរៀបចំសម្តែងសិល្បៈរួម អាស៊ាន-ចិន ចាប់ពីថ្ងៃទី២៦ ដល់ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ នៅខេត្តសៀមរាប ឲ្យទទួលបានជោគជ័យ។

**ប្រការ២:_**

ត្រូវបានបង្កើតលេខាធិការដ្ឋាន និងអនុគណៈកម្មការ នៃគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំកម្មវិធីសម្តែងសិល្បៈអាស៊ាន-ចិន ដែលមានសមាសភាព និងភារកិច្ចដូចខាងក្រោម៖

**ក.លេខាធិការដ្ឋាន**

១- ឯកឧត្តម **គង់ សូលីដា** អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុនៃក្រសួងទេសចរណ៍ ប្រធាន

២. ឯកឧត្តម **អ៊ុក សោភ័ណ** អគ្គនាយកនៃអគ្គនាយកដ្ឋានអាស៊ាននៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៣-លោក **ផ្លុង ធឿន** អគ្គនាយករង និងជាប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅនៃក្រសួងទេសចរណ៍ អនុប្រធាន

៤. លោក **យៀប សំណាង** អគ្គនាយករងនៃអគ្គនាយកដ្ឋានអាស៊ាននៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៥. លោក **កែវ ភាន់វីរៈ** ប្រធាននាយកដ្ឋានសហប្រតិបត្តិការវប្បធម៌អន្តរជាតិ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

៦. លោក **ម៉ែន វណ្ណា** អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងគណនេយ្យ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៧- លោកស្រី **សំ កញ្ញាសាឡូន** ជំនួយការឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ សមាជិក

៨- លោក **គឹម រ៉ាវី** អនុប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប សមាជិក

៩- លោកស្រី **សារិន កញ្ញានា** នាយការិយាល័យរដ្ឋបាលនិងរបៀបនៃក្រសួងទេសចរណ៍ សមាជិក

១០- លោក **ប៉ែន សុវណ្ណា** នាយការិយាល័យសរុបនៃក្រសួងទេសចរណ៍ សមាជិក

១១- កញ្ញា **ទ្រី សុខឡា** នាយរងការិយាល័យរដ្ឋបាលនៃក្រសួងទេសចរណ៍ សមាជិក

១២- លោក **អៀង សុគុណា** ជំនួយការឯកឧត្តមអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ សមាជិក

១៣.លោក **វង់ មនោ** មន្ត្រីនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ សមាជិក

១៤- កញ្ញា **ជេដ្ឋា សេរីវឌ្ឍនា** មន្ត្រីនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ សមាជិក

១៥- កញ្ញា **ខុម ចរិយា** មន្ត្រីនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ សមាជិក

១៦- លោក **អៀង វណ្ណះ** មន្ត្រីនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ សមាជិក

លេខាធិការដ្ឋាននេះមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ជាជំនួយដល់គណៈកម្មការក្នុងការដឹកនាំ ចាត់ចែង ត្រួតពិនិត្យ សម្របសម្រួលជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
- រៀបចំកិច្ចប្រជុំបច្ចេកទេសនានាសម្រាប់គណៈកម្មការអន្តរក្រសួង
- រៀបចំលិខិតអញ្ជើញភ្ញៀវជាតិ និងអន្តរជាតិចូលរួមពិធីបើកកម្មវិធីសម្តែងសិល្បៈរួមអាស៊ាន-ចិន
- រៀបចំបញ្ជីឈ្មោះភ្ញៀវជាតិ និងអន្តរជាតិចូលរួមពិធីបើកកម្មវិធីសម្តែងសិល្បៈរួមអាស៊ាន-ចិន
- រៀបចំស្លាកពាក់សម្រាប់ភ្ញៀវជាតិ-អន្តរជាតិចូលរួមពិធីបើកកម្មវិធីសម្តែងសិល្បៈរួមអាស៊ាន-ចិន
- រៀបចំប័ណ្ណចតរថយន្តសម្រាប់ភ្ញៀវជាតិ-អន្តរជាតិចូលរួមពិធីបើកកម្មវិធីសម្តែងសិល្បៈរួមអាស៊ាន-ចិន
- រៀបចំរបាយការណ៍បូកសរុបលទ្ធផលកម្មវិធីសម្តែងសិល្បៈរួមអាស៊ាន-ចិនជូនរាជរដ្ឋាភិបាល
- ទទួលភារកិច្ចផ្សេងៗទៀតដែលប្រធានគណៈកម្មការអន្តរក្រសួងប្រគល់ជូន។

**ខ. អនុគណៈកម្មការឃោសនាផ្សព្វផ្សាយនិងរៀបចំទស្សនីយភាពសិល្បៈ**

| | | |
|---|---|---|
| ១. លោកជំទាវ **ម៉ិញ អុសនី** | រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សហប្រធាន |
| ២. ឯកឧត្តម **ប៉ាក់ សុខុម** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សហប្រធាន |
| ៣. ឯកឧត្តម **ជា ចាន់បរិបូរណ៍** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | អនុប្រធាន |
| ៤. ឯកឧត្តម **គឹម គុណាវឌ្ឍន៍** | ប្រតិភូរាជរដ្ឋាភិបាល-អគ្គនាយកទូរទស្សន៍ជាតិកម្ពុជា | សមាជិក |
| ៥. ឯកឧត្តម **សូ វិសុទ្ធី** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៦. ឯកឧត្តម **ហាប់ ទូច** | អគ្គនាយកបច្ចេកទេសនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៧. ឯកឧត្តមបណ្ឌិត **ប្រុំ សុវត្ថិ** | សាកលវិទ្យាធិការសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៨. ឯកឧត្តមបណ្ឌិត **សំ សំអាង** | ទីប្រឹក្សាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៩. ឯកឧត្តម **ម៉ៅ កេង** | ទីប្រឹក្សាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១០.ឯកឧត្តម **គ្រឿង ឈាង** | ទីប្រឹក្សាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១១.លោក **ឃិន ស៊ីផេង** | អគ្គនាយករងទេសចរណ៍នៃក្រសួងទេសចរណ៍ | សមាជិក |
| ១២.លោកស្រី **តឹក សុភី** | អគ្គនាយករងទេសចរណ៍នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៣.លោក **ហេង សុខចំរើន** | អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុនៃក្រសួងទេសចរណ៍ | សមាជិក |
| ១៤.លោក **ឡោ ធូរ៉ា** | ប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយនៃក្រសួងទេសចរណ៍ | សមាជិក |
| ១៥.លោក **ម៉ុត ចាន់ណា** | ប្រធាននាយកដ្ឋានសិល្បៈ និងទស្សនីយភាពនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៦.លោក **កែវ ភាន់វីរៈ** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការវប្បធម៌អន្តរជាតិ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៧.លោក **ឃិត ចាន់ដារដ្ឋ** | ប្រធាននាយកដ្ឋានស្តីទីអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌនៃអាជ្ញាធរអប្សរា | សមាជិក |
| ១៨- លោក **ខ៊ុំ សេងភាក់** | ប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប | សមាជិក |

១៩.លោក **ឆឹង មុន្នី** អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
នៃក្រសួងទេសចរណ៍ សមាជិក

២០.លោក **សុខ ស៊ីណារិទ្ធ** អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ
នៃក្រសួងទេសចរណ៍ សមាជិក

២១.លោក **លី ចណ្ណា:** អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ
នៃក្រសួងទេសចរណ៍ សមាជិក

២២.លោក **តាត ចិសុទ្ធមុនី** នាយការិយាល័យ នាយកដ្ឋានសិក្សាទីផ្សារ
និងផ្សព្វផ្សាយនៃក្រសួងទេសចរណ៍ សមាជិក

២៣.លោក **សុខ សំអាត** នាយការិយាល័យ នាយកដ្ឋានសិក្សាទីផ្សារ
និងផ្សព្វផ្សាយនៃក្រសួងទេសចរណ៍ សមាជិក

២៤.លោក **មាស ជូណារ៉ា**ជំនួយការ ឯកឧត្តម ប៉ាក់ សុខុម រដ្ឋលេខាធិការ
នៃក្រសួងទេសចរណ៍ សមាជិក

២៥.លោក **ភាំង សុខចំរើន** មន្ត្រីនាយកដ្ឋានអប់រំបណ្តុះបណ្តាល
នៃក្រសួងទេសចរណ៍ សមាជិក

២៧.លោក **ស្រី សំនិត** មន្ត្រីនាយកដ្ឋានអប់រំបណ្តុះបណ្តាល
នៃក្រសួងទេសចរណ៍ សមាជិក

**អនុគណៈកម្មការនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

- ផលិតសម្ភារៈ និងឯកសារឃោសនាផ្សព្វផ្សាយនានា
- ធ្វើការឃោសនាផ្សព្វផ្សាយពីព្រឹត្តិការណ៍នេះតាមគ្រប់រូបភាព និងមធ្យោបាយ ដោយសហការជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងស្រុក និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- រៀបចំកម្មវិធីសម្តែងសិល្បៈរួមអាស៊ាន-ចិន
- សហការជាមួយអាជ្ញាធរអប្សរា សាលាខេត្តសៀមរាប រៀបចំទីកន្លែងសម្តែងទស្សនីយភាពសិល្បៈក្នុងបរិវេណប្រាសាទបាយ័ន
- រៀបចំទស្សនីយភាពសិល្បៈកម្ពុជាសម្រាប់ការសម្តែងក្នុងព្រឹត្តិការណ៍សម្តែងសិល្បៈរួមអាស៊ាន-ចិន
- រៀបចំពិធីបើក និងបិទព្រឹត្តិការណ៍សម្តែងសិល្បៈរួមអាស៊ាន-ចិន។

**គ. អនុគណៈកម្មការរៀបចំឯកសារ ខ្លឹមសារ និងកិច្ចប្រជុំ**

១. លោកជំទាវ **សឿង រដ្ឋចារី** រដ្ឋលេខាធិការក្រសួងការបរទេស និង
សហប្រតិបត្តិការអន្តរជាតិ សហប្រធាន

២. ឯកឧត្តម **ថិត ចន្ថា** រដ្ឋលេខាធិការក្រសួងទេសចរណ៍ សហប្រធាន

៣. ឯកឧត្តម **ភាន់ ផារិទ្ធ** អនុរដ្ឋលេខាធិការក្រសួងការបរទេស និង
សហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៤. ឯកឧត្តម **ឈោប សាមុត** អគ្គនាយកទេសចរណ៍ និងជាអគ្គលេខាធិការ
គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត អនុប្រធាន

៥. ឯកឧត្តម **អ៊ុក សោភ័ណ** អគ្គនាយក នៃអគ្គនាយកដ្ឋានអាស៊ាន
ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

| | | |
|---|---|---|
| ៦. ឯកឧត្តម **ហាប់ ទូច** | អគ្គនាយកបច្ចេកទេសនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៧. ឯកឧត្តម **អាំង សុវណ្ណារ័ត្ន** | អគ្គនាយករងទេសចរណ៍និងជាអគ្គលេខាធិការរង គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត | សមាជិក |
| ៨. ឯកឧត្តម **ជា កុសល** | ទីប្រឹក្សាក្រសួង និងជានាយកខុទ្ទកាល័យរដ្ឋមន្ត្រី ក្រសួងទេសចរណ៍ | សមាជិក |
| ៩. លោក **កើត ពុទ្ធថរី** | អគ្គនាយករងទេសចរណ៍នៃក្រសួងទេសចរណ៍ | សមាជិក |
| ១០.លោក **យៀប សំណាង** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអាស៊ាននៃក្រសួង ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១១.លោកស្រី **ថោង សុគន្ធារី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអាស៊ាន នៃ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១២.លោក **ជុក ជំនោរ** | ប្រធាននាយកដ្ឋានទេសចរណ៍មេណីយដ្ឋាននិងវប្បធម៌ | សមាជិក |
| ១៣.លោក **កែវ ភាន់ថិរៈ** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការវប្បធម៌អន្តរជាតិ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៤.លោក **លី វណ្ណា** | ប្រធាននាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ នៃអាជ្ញាធរអប្សរា | សមាជិក |
| ១៥.លោក **ឈូក ម៉ុណ្ណា** | អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៦.កញ្ញា **ម៉ក់ សុធីតា** | អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៧.កញ្ញា **លាងស៊ាម លេក្ខាលីស** | សមាជិកក្រុមលេខាសម្តេចតេជោនាយករដ្ឋមន្ត្រី | សមាជិក |
| ១៨.លោក **គាំ សារឿន** | ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៩.លោក **ហេង ហុក** | ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២០.លោកស្រី **ឈុន ចាន់នីម៉ា** | ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២១.កញ្ញា **ជា សុម៉ាលី** | ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២២.កញ្ញា **តាន់ សូលីតា** | ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២៣.កញ្ញា **ឆាយ រស្មី** | ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២៤.កញ្ញា **ឈួន ស្រីនួ** | អនុប្រធានការិយាល័យនៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

| | | |
|---|---|---|
| ២៥.កញ្ញា **ខឡូនា នីកា** | អនុប្រធានការិយាល័យនៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២៦.លោក **ជា តារ័ត្ន** | មន្ត្រីនៃអគ្គនាយកដ្ឋានអាស៊ានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

អនុគណៈកម្មការនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំខ្លឹមសារឯកសារពាក់ព័ន្ធនានាសម្រាប់ដំណើរការកិច្ចប្រជុំ
- រៀបចំបោះពុម្ពឯកសារសំខាន់ៗពាក់ព័ន្ធ និងកិច្ចប្រជុំ
- ផ្សព្វផ្សាយឲ្យបានទូលំទូលាយតាមគ្រប់មធ្យោបាយ គ្រប់រូបភាពទាំងក្នុង និងក្រៅប្រទេស តាមរយៈគេហទំព័រ ទូរទស្សន៍ វិទ្យុ បដា ពាក្យស្លោក ផ្ទាំងប៉ាណូតូច-ធំ
- ធ្វើរបាយការណ៍ពីលទ្ធផលនៃកិច្ចប្រជុំ និងការសម្តែងសិល្បៈជូនរាជរដ្ឋាភិបាល។

### ឃ. អនុគណៈកម្មការព័ត៌មាន និងផ្សព្វផ្សាយ

| | | |
|---|---|---|
| ១. ឯកឧត្តម **ជា ចាន់បរិបូរណ៍** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | ប្រធាន |
| ២. ឯកឧត្តម **គឹម គុណាវឌ្ឍន៍** | ប្រតិភូរាជរដ្ឋាភិបាល-អគ្គនាយកទូរទស្សន៍ជាតិកម្ពុជា | អនុប្រធាន |
| ៣. លោកជំទាវ **សុខមុំ និមល** | អគ្គនាយិកាទីភ្នាក់ងារសារព័ត៌មានAKP | សមាជិក |
| ៤. ឯកឧត្តម **ផុស សុវណ្ណ** | អគ្គនាយកព័ត៌មាន និងសោទស្សន៍ | សមាជិក |
| ៥. ឯកឧត្តម **ទន់ សារ៉ាត់** | អគ្គនាយកវិទ្យុជាតិកម្ពុជា | សមាជិក |
| ៦. លោក **ហុក សុតា** | ប្រធាននាយកដ្ឋានសារព័ត៌មាន នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៧. លោក **ឡុង កុសល** | ប្រធាននាយកដ្ឋានផ្សព្វផ្សាយនៃអាជ្ញាធរអប្សរា | សមាជិក |
| ៨. លោក **គង់ សុតារក្យ** | ប្រធាននាយកដ្ឋានស្ថិតិ និងព័ត៌មានទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ៩. លោក **ប្រាក់ ឧទ្ធី** | អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១០. លោក **ចៅ វណ្ណរិទ្ធ** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១១.លោក **ព្រំ អធិតា** | អនុប្រធានការិយាល័យនៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១២.កញ្ញា **កុក រចនា** | មន្ត្រីនៃអគ្គនាយកដ្ឋានអាស៊ានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៣. កញ្ញា **ហោ ដូល្លា** | មន្ត្រីនៃអគ្គនាយកដ្ឋានអាស៊ានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

អនុគណៈកម្មការនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សហការជាមួយអនុគណៈកម្មការរៀបចំឯកសារ ខ្លឹមសារកិច្ចប្រជុំ ដើម្បីរៀបចំអត្ថបទព័ត៌មាន ដើម្បីផ្សព្វផ្សាយអំពីព្រឹត្តិការណ៍នៃការសម្តែងសិល្បៈរួមអាស៊ាន-ចិន

- ផ្សព្វផ្សាយនូវព័ត៌មាននៃព្រឹត្តិការណ៍សម្តែងសិល្បៈរួមអាស៊ាន-ចិន មុន និងអំឡុងពេលនៃការរៀបចំកម្មវិធី តាមរយៈគេហទំព័រ ទូរទស្សន៍ វិទ្យុ បដា ពាក្យស្លោក ផ្ទាំងប៉ាណូតូច-ធំ
- រៀបចំចងក្រងនូវឯកសារវីឌីអូនៃសកម្មភាពកម្មវិធីសម្តែងសិល្បៈទាំងមូល។

**ខ. អនុគណៈកម្មការរៀបចំបដិសណ្ឋារកិច្ច ពិធីការ និងដឹកជញ្ជូនដំណើរទស្សនកិច្ច**

| | | |
|---|---|---|
| ១. ឯកឧត្តម **លុយ ដាវីត** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២. ឯកឧត្តម **សុខ តុងហាប់** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣.លោកជំទាវ **យូ សុតា** | អភិបាលរងខេត្តសៀមរាប | អនុប្រធាន |
| ៤. លោក **ផ្លុង ធឿន** | អគ្គនាយករង និងជាប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅនៃក្រសួងទេសចរណ៍ | សមាជិក |
| ៥. លោក **នឹម សុវណ្ណា** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ | សមាជិក |
| ៦. លោក **ហេង សុដានី** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ | សមាជិក |
| ៧. លោក **ប៊ុត ចាន់ណា** | ប្រធាននាយកដ្ឋានសិល្បៈ និងទស្សនីយភាព នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៨. លោក **ខៀវ រិទ្ធីយ៉ា** | ប្រធាននាយកដ្ឋានពិធីការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៩.លោក **ថូ សំណាង** | ប្រធាននាយកដ្ឋានកុងស៊ុលនៃក្រសួង ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១០.លោក **អៀ ឧត្តារ៉ា** | ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១១.លោក **ទ៉ូច សេងភាក់** | ប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប | សមាជិក |
| ១២.លោក **សៅ ច័ន្ទពិសិដ្ឋ** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៣.លោក **ស៊ិន ស៊ីយ៉ា** | អនុប្រធាននាយកដ្ឋាននៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៤.លោកស្រី **អ៊ុំ ម៉ារ៉ាឌី** | អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍នៃអាជ្ញាធរអប្សរា | សមាជិក |
| ១៥.លោក **ជុំ អច្ចវិចិត្រ** | អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៦.លោក **មុយ សែ** | អនុប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៧.លោកស្រី **ឯម ច៉ាន់សារ៉ារ័ត្ន** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ ក្រសួងទេសចរណ៍ | សមាជិក |
| ១៨.កញ្ញា **នៀម ភញ្ញនា** | ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

| | | |
|---|---|---|
| ១៩.លោក **សាក់ ម៉ូនីរ៉េត** | ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២០.កញ្ញា **ម៉ាឡា មូនារី** | ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២១.លោកស្រី **ឃុ សុគន្ធារី** | នាយការិយាល័យពិធីការនៃក្រសួងទេសចរណ៍ | សមាជិក |
| ២២.លោក **តែ អ៊ាងឆេង** | អនុប្រធានការិយាល័យនៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២៣.លោក **តុង តេរ៉េង** | អនុប្រធានការិយាល័យនៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២៤.លោក **សួស សង្វាត** | អនុប្រធានការិយាល័យនៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២៥.កញ្ញា **ជិន ផានិត** | នាយរងការិយាល័យពិធីការក្រសួងទេសចរណ៍ | សមាជិក |
| ២៦.កញ្ញា **រ៉េតករុណា** | មន្ត្រីពិធីការនៃក្រសួងទេសចរណ៍ | សមាជិក |
| ២៧.កញ្ញា **នូ សុផ្លានី** | មន្ត្រីពិធីការនៃក្រសួងទេសចរណ៍ | សមាជិក |
| ២៨.លោក **ឈឺន សុខឡា** | មន្ត្រីនៃអគ្គនាយកដ្ឋានអាស៊ានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២៩.លោក **ទង់ ច័ន្ទរតនៈ** | មន្ត្រីនៃអគ្គនាយកដ្ឋានអាស៊ានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៣០.លោក **ឃុត សេងពន្លឺ** | មន្ត្រីនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ នៃក្រសួងទេសចរណ៍ | សមាជិក |
| ៣១.លោក **អៀង សេងហេង** | មន្ត្រីនៃអគ្គនាយកដ្ឋានអាស៊ានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៣២.លោក **ចែម វណ្ណាវរឫទ្ធិ** | មន្ត្រីនៃអគ្គនាយកដ្ឋានអាស៊ានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៣៣.លោក **ឌិន កុសល** | មន្ត្រីនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ នៃក្រសួងទេសចរណ៍ | សមាជិក |
| ៣៤.លោក **ឌុន ផានិត** | មន្ត្រីនៃអគ្គនាយកដ្ឋានអាស៊ានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

**អនុគណៈកម្មការនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

-រៀបចំវេទិកាគណៈអធិបតី កន្លែងអង្គុយ និងពិធីការសម្រាប់ឥស្សរជនជាតិ និងអន្តរជាតិ

- រៀបចំទទួលស្វាគមន៍គណៈប្រតិភូជាតិ និងអន្តរជាតិ

- សហការជាមួយអនុកម្មការឃោសនាផ្សព្វផ្សាយរៀបចំពិធីបើក និងបិទការសម្តែងសិល្បៈរួម អាស៊ាន-ចិន នៅខេត្តសៀមរាប

- រៀបចំដឹកជញ្ជូន និងខ្សែទស្សនកិច្ចជូនភ្ញៀវជាតិ និងអន្តរជាតិ

- រៀបចំ និងសម្រួលការស្នាក់នៅ ដឹកជញ្ជូន និងហូបចុករបស់គណៈប្រតិភូជាតិ និងអន្តរជាតិ។

**ច.អនុគណៈកម្មការការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ សុខភាព និងសង្គ្រោះបន្ទាន់**

| | | |
|---|---|---|
| ១.ឯកឧត្តមឧត្តមសនីយ៍ឯក **ទូច ណារុថ** អគ្គស្នងការរងនគរបាលជាតិ | | ប្រធាន |
| ២. ឯកឧត្តមឧត្តមសនីយ៍ឯក **ខេង ពិសេន** | មេបញ្ជាការរង និងជានាយសេនាធិការនៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| ៣.ឯកឧត្តម **ពៅ ពិសិដ្ឋ** | អភិបាលរងខេត្តសៀមរាប | អនុប្រធាន |
| ៤.ឯកឧត្តម **ប្រាក់ ច័ន្ទតារា** | អគ្គនាយករងទេសចរណ៍ | សមាជិក |
| ៥.ឧត្តមសេនីយ៍ឯក **សំ ស៊ីយ៉ាន** | ប្រធាននាយកដ្ឋាននគរបាលទេសចរណ៍នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៦.ឧត្តមសេនីយ៍ទោ **ស៊ិត ណាឌី** | ស្នងការនគរបាលខេត្តសៀមរាប | សមាជិក |
| ៧.ឧត្តមសេនីយ៍ត្រី **ប៉ោ វណ្ណនិត** | មេបញ្ជាការកងរាជអាវុធហត្ថខេត្តសៀមរាប | សមាជិក |
| ៨.ឧត្តមសេនីយ៍ត្រី **ស៊ិន តាត់** | មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តសៀមរាប | សមាជិក |
| ៩.លោកវេជ្ជបណ្ឌិត **សុខ ស្រ៊ុន** | ប្រធាននាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល | សមាជិក |
| ១០.លោក **គង់ មករេត** | ប្រធាននាយកដ្ឋានស្តីទីសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការនៃអាជ្ញាធរអប្សរា | សមាជិក |
| ១១.វរសេនីយ៍ឯក **គាត ម៉ុនថាន** | ប្រធានអង្គភាពការពារបេតិកភណ្ឌក្រសួងមហាផ្ទៃ | សមាជិក |
| ១២. លោក **ទូន សេដា** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅនៃក្រសួងទេសចរណ៍ | សមាជិក |
| ១៣. លោក **សោ ទិសិដ្ឋ** | អនុប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប | សមាជិក |
| ១៤. លោក **ចឹក តារុន** | នាយការិយាល័យសន្តិសុខ សុវត្ថិភាពទេសចរណ៍នៃក្រសួងទេសចរណ៍ | សមាជិក |

អនុគណៈកម្មការនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំការពារសន្តិសុខ របៀបរបប សណ្តាប់ធ្នាប់ និងចរាចរ និងធានាសុវត្ថិភាពឲ្យបានគ្រប់គ្រាន់ នៅមុន និងក្រោយពេលប្រារព្ធពិធី និងតាមផ្លូវឆ្លងកាត់
- ទំនាក់ទំនង និងសហការជិតស្និទ្ធជាមួយអាជ្ញាធរមានសមត្ថកិច្ចនៅអាកាសយានដ្ឋានអន្តរជាតិ និងតាមច្រកទ្វារព្រំដែនអន្តរជាតិ ដើម្បីបង្ករលក្ខណៈងាយស្រួលដល់គណៈប្រតិភូ និងភ្ញៀវអន្តរជាតិដែលអញ្ជើញចូលរួម
- ត្រៀមលក្ខណៈ និងមធ្យោបាយគ្រប់គ្រាន់សម្រាប់សង្គ្រោះបន្ទាន់ ក្នុងករណីមានបាតុភាពជាយថាហេតុ
- រថយន្តពេទ្យ គ្រូពេទ្យ ថ្នាំពេទ្យ សម្រាប់ជួយបម្រើសុខភាពភ្ញៀវ។

**ឆ.អនុគណៈកម្មការហិរញ្ញវត្ថុ**

| | | |
|---|---|---|
| ១. ឯកឧត្តម **សុខ សុខហាប់** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សហប្រធាន |
| ២.ឯកឧត្តម **ហ៊ើល ចំរើន** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សហប្រធាន |
| ៣.ឯកឧត្តម **ញឹម ខេមរា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |

| | | |
|---|---|---|
| ៤. ឯកឧត្តម **គង់ សុលីដា** | អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុនៃក្រសួងទេសចរណ៍ | អនុប្រធាន |
| ៥. លោកជំទាវ **លឹម មុំ** | អគ្គនាយិការដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងព័ត៌មាន | សមាជិក |
| ៦. លោក **ពៅ ភញ្ញា** | ប្រធានក្រុមមន្ត្រីត្រួតពិនិត្យអមក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៧.លោក **អៀ ឌុស្តាវ៉ា** | ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ | សមាជិក |
| ៨. លោក **តិន ទិដ្ឋាវឌ្ឍនា** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ គណនេយ្យនៃក្រសួង ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៩. លោក **លន់ ហួរ** | ប្រធាននាយកដ្ឋានផែនការ គណនេយ្យ និង ហិរញ្ញកិច្ចនៃក្រសួងព័ត៌មាន | សមាជិក |
| ១០.លោក **ម៉ែន វណ្ណា** | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ គណនេយ្យនៃ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

**អនុគណៈកម្មការនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

- គ្រប់គ្រង និងចាត់ចែងការងារហិរញ្ញវត្ថុ ចំណូល ចំណាយ គ្រប់សកម្មភាពនៃដំណើរការរៀបចំការសម្តែងសិល្បៈរួមអាស៊ាន-ចិន
- បូកសរុបចំណូល-ចំណាយ។

**ប្រការ៣.**_

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការ ឬក្រុមការងារបន្ថែម តាមការចាំបាច់។ អនុគណៈកម្មការនីមួយៗ និងលេខាធិការដ្ឋាន អាចស្នើសុំជ្រើសរើសសមាជិកបន្ថែមតាមការចាំបាច់ ដោយមានការយល់ព្រមពីប្រធានគណៈកម្មការអន្តរក្រសួង។

**ប្រការ៤.**_

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ថវិការបស់រាជរដ្ឋាភិបាល និងប្រភពថវិកាស្របច្បាប់ផ្សេងៗទៀត ដើម្បីដំណើរការការងាររបស់ខ្លួន។

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិស្វែងរកដៃគូអភិវឌ្ឍន៍ ឬផ្នែកឯកជន ដើម្បីជួយទ្រទ្រង់ និងឧបត្ថម្ភដល់ដំណើរការរៀបចំការសម្តែងសិល្បៈរួមអាស៊ាន-ចិននេះ។

**ប្រការ៥.**_

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងទេសចរណ៍ ដើម្បីដំណើរការការងាររបស់ខ្លួនតាមការចាំបាច់។

អនុប្រធាន សមាជិកគណៈកម្មការ ប្រធាន អនុប្រធាន សមាជិកអនុគណៈកម្មការ និងលេខាធិការដ្ឋាន ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការអន្តរក្រសួង។

**ប្រការ៦.**_

គណៈកម្មការអន្តរក្រសួងនេះ នឹងត្រូវរំសាយក្រោយពេលចប់ភារកិច្ច។

**ប្រការ៧.**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៨.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ប្រការ២ ត្រូវទទួលអនុវត្តតាមសេចក្តីសម្រេចនេះឱ្យមាន ប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៣០ សសរ

# សេចក្ដីសម្រេច

# ស្ដីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## <u>សម្រេច</u>

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនសម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្ដីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវអញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា ទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៦ រហូតដល់ពេលសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន អភិបាលរាជធានី អភិបាលគ្រប់ខេត្ត និងសម្ដេចក្រឡាហោម **ស ខេង** ត្រូវអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល**</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ..........សហវ.ប្រក

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការតែងតាំងរដ្ឋលេខាធិការប្រតិភូរាជរដ្ឋាភិបាល… 

# នៅក្រសួងកិច្ចការនារី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងកិច្ចការនារី**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/១៣៩៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នរ/រកម/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការវិសោធនកម្ម មាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ៨២ អនក.ប្រក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក.ប្រក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តមាតិកា គណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ ១៦ និងប្រការ ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងកិច្ចការនារី

## សម្រេច

**ប្រការ១**: _

ត្រូវបានតែងតាំងមន្ត្រីរាជការនៃក្រសួងកិច្ចការនារី ដែលមានសមាភាពដូចខាងក្រោះ

១- លោក **ធៀម គមហ្វ** អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់ ជារជ្ជទេយ្យករបុរេប្រទាន

២- លោកស្រី **គង់ ឫទ្ធី** អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់ ជារជ្ជទេយ្យករបុរេប្រទានរង

**ប្រការ២**:_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣**: _

នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ នៃក្រសួងកិច្ចការនារី ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងកិច្ចការនារី ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួង នេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងកិច្ចការនារី**

**អ៊ឹង កន្ថាផាវី**

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ